**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពីកម្មវិធី «ពិព័រណ៍ការងារ» នៅអគារ KAMPUS

ថ្ងៃព្រហស្បតិ៍ ៩រោច ខែជេស្ឋ ដល់ថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ត្រូវនឹងថ្ងៃទី២៣-២៤ ខែមិថុនា ឆ្នាំ២០២២

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដល់ក្រសួង ស្ថាប័ន និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកស្វែងរកការងារ សិស្ស-និស្សិត និងសាធារណជនមេត្តាជ្រាបថា ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមកិច្ចសហការជាមួយ សហភាពសហព័ន្ធយុវជនកម្ពុជា (UYFC) រាជធានីភ្នំពេញ និងឧបត្ថម្ភគាំទ្រដោយអង្គការអន្តរជាតិខាងការងារ (ILO) នឹងរៀបចំកម្មវិធី «**ពិព័រណ៍ការងារ**» ដែលនឹងប្រព្រឹត្តទៅរយៈពេល ០២ថ្ងៃ គឺចាប់ពីថ្ងៃព្រហស្បតិ៍ ៩រោច ខែជេស្ឋ ដល់ថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៣-២៤ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៨:០០នាទីព្រឹក ដល់ម៉ោង ១៧:០០ នាទីល្ងាច នៅទីតាំងអគារ Kampus ជិតស្ពានអាកាសក្បាលថ្នល់។

កម្មវិធីពិព័រណ៍ការងារនេះ ត្រូវបានរៀបចំឡើងជាវេទិកាជួបជុំគ្នាដោយងាយស្រួលនៅមួយកន្លែងរវាងនិយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងអ្នកស្វែងរកការងារ ដើម្បីផ្សព្វផ្សាយព័ត៌មានឱកាសការងារ ជ្រើសរើសកម្លាំងពលកម្ម ដាក់ពាក្យស្នើសុំការងារ និងព័ត៌មានស្តីពីការបណ្តុះបណ្តាលជំនាញ ព្រមទាំងសិក្ខាសាលាចែករំលែកបទពិសោធន៍ ការប្រឹក្សាយោបល់ការងារ អាជីព និងត្រៀមខ្លួនចូលការងារ ដោយវាគ្មិនដែលមានបទពិសោធន៍ជ្រាលជ្រៅក្នុងទីផ្សារការងារ។ ក្នុងព្រឹត្តិការណ៍ពិព័រណ៍ការងារនេះ នឹងមានក្រុមហ៊ុនធំៗចំនួន ២២ ចូលរួមតាំងបង្ហាញអំពីតម្រូវការជ្រើសរើសកម្លាំងពលកម្មប្រមាណ ៣,២០០កន្លែង ហើយសង្ឃឹមថា នឹងទាក់ទាញអ្នកចូលរួម និងដាក់ពាក្យរកការងារ ដែលជាយុវជន និងកម្លាំងពលកម្មវ័យក្មេងរាប់ពាន់នាក់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រប់ក្រសួង ស្ថាប័ន ក្រុមហ៊ុន សហគ្រាស អង្គការជាតិ/អន្តរជាតិ អ្នកស្វែងរកការងារ និងសាធារណជន ជ្រាបជាព័ត៌មាន និងចូលរួមឱ្យបានច្រើនកុះករ។ សម្រាប់ព័ត៌មានពិស្តារស្តីពីពិព័រណ៍ការងារនេះ សូមទំនាក់ទំនងមកកាន់ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ព័ត៌មានបន្ថែមស្តីពីកម្មវិធីពិព័រណ៍សូមស្កេន QR Code ឬទាក់ទងតាមរយៈលេខទូរស័ព្ទ ០១៧ ៤៦៧៤២៣/ ០១៧ ៨៧១ ៨០៧/០៩៦ ២១៥៥ ១៦២។

ថ្ងៃ ចន្ទ ៦រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២

ព័ត៌មានបន្ថែម

ស្តីពីកម្មវិធីពិព័រណ៍

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩